## ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) មានការព្រួយបារម្ភយ៉ាងខ្លាំង ដោយការកាត់ទោស ព្រោះតែការបង្ហោះលើហ្វេសប៊ុកនៅកម្ពុជា

ទីក្រុងបាងកក (១៨ មីនា ២០១៦) - ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ប្រចាំតំបន់អាស៊ីអាគ្នេយ៍ (ការិយាល័យ OHCHR) មានការព្រួយបារម្ភយ៉ាងខ្លាំង ដោយការកាត់ទោសនិស្សិតសាកលវិទ្យាល័យមួយរូប ឈ្មោះ គង់ រ៉ាយ៉ា ដោយតុលាការកម្ពុជា ដោយសារតែសារប្រឆាំងរដ្ឋាភិបាល ដែលនិស្សិតរូបនេះបានបង្ហោះលើហ្វេសប៊ុក។

លោក រ៉ាយ៉ា ត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម ដោយសារតែការបង្ហោះលើទំព័រហ្វេសប៊ុករបស់គាត់ផ្ទាល់ថា "នៅថ្ងៃណាមួយ នៅថ្ងៃអនាគត [ខ្ញុំនឹង] ធ្វើបដិវត្តន៍ពណ៌ដើម្បីផ្លាស់ប្តូររបបសម្រាប់សង្គមខ្មែរ"។ គាត់ត្រូវបានចាប់ខ្លួន ក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីគាត់បានបង្ហោះមតិយោបល់នោះ នៅក្នុងខែសីហា ឆ្នាំ២០១៥។

និស្សិតវ័យ ២៥ ឆ្នាំរូបនេះ ជានិស្សិតនៅសាកលវិទ្យាល័យខេមរៈ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦។ គាត់បានជាប់ឃុំបណ្តោះអាសន្នរយៈពេលប្រាំមួយខែរួចហើយ គាត់ត្រូវប្រឈមនឹងទោសជាប់ពន្ធនាគាររយៈពេលមួយឆ្នាំបន្ថែមទៀត។

របាយការណ៍បញ្ជាក់ថា លោក រ៉ាយ៉ា គឺជាជនជាតិខ្មែរដំបូងគេ ដែលត្រូវបានផ្តន្ទាទោសដោយសារតែការបង្ហោះលើបណ្តាញសង្គម។

"សេរីភាពនៃការសម្តែងមតិ គឺជាសិទ្ធិរបស់ពលរដ្ឋគ្រប់រូប និងជាសមាសធាតុដ៏សំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យពិតប្រាកដ" នេះបើតាមប្រសាសន៍របស់ លោក ឡូរ៉ង់ត៍ មាលឡិន (Laurent Meillan) តំណាងស្តីទីនៃការិយាល័យ OHCHR ប្រចាំតំបន់ នៅទីក្រុងបាងកក។ "ចំពោះនរណាម្នាក់ដែលប្រឈមនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ព្រោះតែការអនុវត្តសិទ្ធិនេះ - ជាពិសេសចំពោះអ្វីដែលជាបញ្ហាផ្ទាល់ខ្លួនសំខាន់ - គឺជាសញ្ញាមួយដែលបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការថមថយនៃលំហប្រជាធិបតេយ្យនៅកម្ពុជា។"

ការិយាល័យ OHCHR ប្រចាំតំបន់ ជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជា បញ្ឈប់ការកាត់ទោសបុគ្គលនានា ដោយគ្រាន់តែការសម្តែងគំនិតប៉ុណ្ណោះ។

លោក មាលឡិន បានមានប្រសាសន៍ ថា "នៅកម្ពុជា មានច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិជាច្រើន ដែលការពារសិទ្ធិសេរីភាពនៃគំនិត និងការសម្តែងមតិ"។ "សិទ្ធិទាំងនេះ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ហើយគួរតែត្រូវបានលើកកម្ពស់ និងគោរព ដោយមន្ត្រីអនុវត្តច្បាប់ និងតុលាការ ផងដែរ។"

ការិយាល័យ OHCHR សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាដើម្បីធ្វើឲ្យប្រាកដថាកម្ពុជាលើកកម្ពស់ការកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិចំពោះសេរីភាពនៃការសម្តែងមតិ។

ចប់

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង លោក ជេរេមី ឡូរ៉េង់ត៍ (Jeremy Laurence) តាមរយៈទូរស័ព្ទ (+៦៦ ៨៤ ៧០០ ៤៦៧១/អ៊ីមែល៖ laurence@un.org)*
ការិយាល័យប្រចាំតំបន់ ប្រចាំនៅតំបន់អាស៊ីអាគ្នេយ៍ នៅទីក្រុងបាងកក *តំណាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅទូទាំងប្រចាំតំបន់អាស៊ីអាគ្នេយ៍។ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សគឺជាមន្ត្រីសិទ្ធិមនុស្សសំខាន់របស់អង្គការសហប្រជាជាតិ និងជាប្រធានការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលទទួលខុសត្រូវដឹកនាំកិច្ចខិតខំប្រឹងប្រែងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។*

*វេបសាយរបស់ការិយាល័យ OHCHR ៖* http://www.ohchr.org

*វេបសាយរបស់រិយាល័យ OHCHR ប្រចាំតំបន់អាស៊ីអាគ្នេយ៍៖http://bangkok.ohchr.org/*